# ប្រពៃណីទំនៀមទម្លាប់ដក់ជាប់លើគំនូរ (ភាគ១)

គំនូរដែលលើកមកនិយាយក្នុងពេលនេះ គឺសំដៅលើគំនូរនៅតាមវត្ត ដែលច្រើនសង្កេតឃើញគូរនៅក្នុងព្រះវិហារ សាលាឆាន់ ឬកុដិព្រះសង្ឃគង់នៅជាដើម។ តាមរយៈការសិក្សាលើគំនូរកន្លងមកគេឃើញយ៉ាងច្បាស់ថា ទោះបីជាសាច់រឿងនៅក្នុងគំនូរទាំងនោះដកស្រង់ចេញពីពុទ្ធប្រវត្តិ និងរឿងជាតកដូចជា ទសជាតក ឬមហាវេស្សន្តរជាតកក៏ជាងគំនូរ តែងប្រើសិល្បៈនិងទេពកោសល្យបញ្ច្រាបគូរបញ្ចូលនូវទិដ្ឋភាពប្រពៃណី និងទំនៀមទម្លាប់នៃសង្គមខ្មែរ ទៅក្នុងសាច់រឿងពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា។ ទិដ្ឋភាពជារឿយៗដែលគេធ្លាប់ប្រទះឃើញមានដូចជា ទំនៀមក្នុងពិធីមង្គលការ ពិធីបុណ្យប្រពៃណីទម្រង់ក្មេង ការលេងល្បែងរបាំកម្សាន្ត សម្លៀកបំពាក់ និងទម្រង់សំណង់លំនៅដ្ឋានរបស់ជនជាតិខ្មែរទៅតាមអន្ទើនីមួយៗ។ ទាំងនេះក៏អាចជាសក្ខីកម្មបង្ហាញថា វត្តអារាមគឺជាមជ្ឈមណ្ឌលនៃការថែរក្សាអត្តសញ្ញាណជាតិ និងជាចំណែកនៃកញ្ចក់ឆ្លុះបញ្ចាំងពីសង្គមខ្មែរតាមសម័យកាល ហើយខ្ញុំសូមលើកបង្ហាញអន្ទើខ្លះដោយត្រួសៗដូចខាងក្រោម។

### ក.ទំនៀមព្រះរាជពិធីច្រត់ព្រះនង្គ័ល

ជាការពិត នៅក្នុងសាច់រឿងពុទ្ធប្រវត្តិបានលើកឡើងថា នាគ្រាមួយនោះព្រះបាទស្រីសុទ្ធោទន៍ ដែលជាព្រះរាជបិតារបស់ព្រះសិទ្ធត្ថ (អនាគតព្រះសម្មាសម្ពុទ្ធ) ទ្រង់យាងចេញច្រត់ព្រះនង្គ័លក្នុងព្រះបរមនាមជាស្តេចផែនដីនៃនគរកបិលពស្តុ។ ក្នុងព្រះរាជពិធីនោះព្រះអង្គបាននាំព្រះសិទ្ធត្ថទៅចូលរួម ហើយទុកឱ្យព្រះសិទ្ធត្ថគង់នៅក្រោមម្លប់ឈើ។ ខណៈនោះ សិទ្ធត្ថកុមារគង់នៅតែម្នាក់ឯង បានសម្រេចចិត្តគង់ភ្នែន ហើយចម្រើនសមាធិពិចារណាអំពីសត្វគោដែលប្រឹងប្រែងអូសនង្គ័លយ៉ាងហត់នឿយ។ ដោយតេជានុភាពដ៏អស្ចារ្យ ម្លប់ឈើមិនឃ្លាតជ្រេទេរទៅទិសខាងណាសោះ ពោលគឺនៅតែបាំងត្រង់ចំពីលើព្រះកាយព្រះសិទ្ធត្ថ ដោយមិនរំកិលទៅតាមពន្លឺព្រះអាទិត្យឡើយ(រូបលេខ១)។[1]

គំនូរនៅត្រង់អន្ទើនៃព្រះរាជពិធីច្រត់ព្រះនង្គ័ល មិនមានគូរទូទៅគ្រប់វត្តឡើយ តែគំនូរនៅព្រះវិហារវត្តព្រះស៊ីសុវត្ថិរតនារាម ក្នុងស្រុកកោះធំ ខេត្តកណ្តាល គេគូរជាទម្រង់

---

[1] Gunapayuta et al, 1998, pp. 33-36

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# *អត្ថបទ៖ ប្រពៃណីទំនៀមទម្លាប់ដក់ជាប់លើគំនូរ (ភាគ១)*

*គំនូរបុរាណដោយបញ្ជាក់សំណេរពីរបន្ទាត់ខាងក្រោមរូបថា "កាលព្រះបាទស្រីសទ្ធោទន (សុទ្ធោទន៍)ទៅច្រតព្រះនង្គ័ល យកព្រះពោធិសត្រ(ព្រះពោធិសត្វ)ទៅផង អោយមេនំមេនាងយកទៅអោយផ្ទុំក្រោមដើមព្រីង"។ ទិដ្ឋភាពក្នុងគំនូរនេះគេឃើញថា ព្រះរាជាទ្រង់យាងច្រត់ព្រះនង្គ័លដោយផ្ទាល់ នៅទីព្រះស្រែ មានមន្ត្រីតូចធំហែហមមុខក្រោយ ហើយនៅម្ខាងមានរៀបភាជន៍៣ ដែលទំនងជាភាជន៍អាហារសម្រាប់ផ្សងគោឧសភរាជ[2] និងនៅឆ្ងាយពីទីព្រះស្រែ គឺមានព្រះសិទ្ធត្ថគង់ក្រោមម្លប់ឈើ(រូបលេខ១)។ សូមបញ្ជាក់ថា ព្រះវិហារនេះបានកសាងឡើងក្រោមព្រះរាជូបត្ថម្ភរបស់* ***ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ "ព្រះរាជានុកោដ្ឋ"*** *ក្នុងឆ្នាំ១៩០៥ ដោយឧកញ៉ាទេពនិម្មិត ម៉ក់[3] តែគំនូរខ្លះជួសជុលឡើងវិញក្នុងទសវត្សរ៍ទី៩០។*




*រូបលេខ១ គំនូរព្រះសុទ្ធោទន៍យាងច្រត់ព្រះនង្គ័លគូរនៅព្រះវិហារព្រះស៊ីសុវត្ថិរតនារាម*

---

[2] *តាមទំនៀមព្រះបរមរាជវាំងសព្វថ្ងៃតែងរៀបអាហារ៧មុខ សម្រាប់ផ្សងគោឧសភរាជគឺ ស្មៅ ស្រា ពោត សណ្តែក ល្ង ស្រូវ និងទឹក។*

[3] *សូមអាន៖ រឹម ទិត្យបញ្ញា "គំនូរក្នុងព្រះវិហារវត្តព្រះស៊ីសុវត្ថិរតនារាម (ភាគ១)" ផ្សាយលើតំណ* https://khmercivilization.ams.com.kh/detail/29371 (*ថ្ងៃ២៧ ធ្នូ ២០២៣*)

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ចំណែកឯគំនូរបង្ហាញទំនៀមច្រត់ព្រះនង្គ័លមួយផ្សេងទៀត គូរនៅវត្តទន្ទាប់រង្សី ក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ជាងគំនូរបានគូរព្រះបាទស្រីសុទ្ធោទន៍ ទ្រង់យាងច្រត់ព្រះនង្គ័លនៅទីព្រះស្រែខាងមុខទីធ្លាប្រាសាទ ដោយមានមហាជនចូលរួមត្រៀបត្រា អ្នកខ្លះភ្ញូកភ្ញឹកមើលក្បួនច្រត់ព្រះនង្គ័ល ឯខ្លះទៀតក៏ងាកមកចាប់អារម្មណ៍ព្រះសិទ្ធត្ថគង់សមាធិក្រោមដើមឈើមួយព្រះអង្គឯង(រូបលេខ២-៣)។ ផ្អែកតាមសំណេរលើជញ្ជាំងខាងកើតព្រះវិហារវត្តនេះចារថា "កសាងពីឆ្នាំឆ្លូវកាលពុទ្ធសករាជ២៤៩២" ដែលកាលបរិច្ឆេទនេះ ត្រូវនឹងរវាងឆ្នាំ១៩៤៩។



រូបលេខ២-៣ គំនូរព្រះសុទ្ធោទន៍យាងច្រត់ព្រះនង្គ័លគូរនៅវត្តទន្ទាប់រង្សី

ប្រហែលហេតុដូចមានបង្ហាញមកខាងដើមនេះ ទើបមានឯកសារខ្លះលើកឡើងថា ទំនៀមច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរ ដែលព្រះរាជាតែងតែប្រារព្ធឡើងជារៀងរាល់ឆ្នាំ ក៏មានឫសគល់ពីក្នុងរឿងពុទ្ធប្រវត្តិ។[4] សូមបញ្ជាក់ថា នៅក្នុងសម័យសង្គមរាស្ត្រនិយម **ព្រះករុណាព្រះបរមរតនកោដ្ឋ** ទ្រង់ធ្លាប់យាងជាព្រះរាជាធិបតីក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លប្រារព្ធនៅព្រះលានជល់ដំរី ក្នុងអតីតក្រុងអង្គរធំ ខេត្តសៀមរាប(រូបលេខ៤-៥)។ ក្រោយព្រះអង្គសោយព្រះទិវង្គត ព្រះរាជពិធីច្រត់ព្រះនង្គ័លក៏ធ្លាប់ប្រារព្ធធ្វើនៅមុខប្រាសាទក្នុងបរិវេណព្រះលានជល់ដំរីម្តងទៀតក្នុងឆ្នាំ២០១៦។

[4] ឈឹម ក្រសេម និង ចាប ពិន, ១៩៥១, ទំ.១៥២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




*រូបលេខ២៨-៩ ព្រះបរមរតនកោដ្ឋ កាលទ្រង់យាងច្រត់ព្រះនង្គ័លក្នុងសម័យសង្គមរាស្ត្រនិយម ប្រារព្ធនៅព្រះលានជល់ដំរី (ប្រភព៖ Royal du Cambodge)*

## ខ.ទំនៀមពិធីអាពាហ៍ពិពាហ៍ (មង្គលការ)

នៅក្នុងគំនូរតាមវត្ត ពិធីរៀបអាពាហ៍ពិពាហ៍ ឬពិធីអភិសេក ភាគច្រើនគូរបង្ហាញនៅក្នុងឈុតរៀបអភិសេកព្រះសិទ្ធត្ថ និងព្រះនាងពិម្ពា។ គំនូរភាគច្រើនតែងគូរតួអង្គទាំងពីរអង្គគង់លើបល្ល័ង្កលើកហត្ថាប្រណម ដូចមានគំនូរបុរាណវត្តកំពង់ត្រឡាចលើ ដែលកសាងឡើងនៅដើមសតវត្សរ៍ទី២០ជាដើម(រូបលេខ២៦)។ ក្នុងពិធីនោះ គំនូរនៅវត្តខ្លះគេតែងសង្កេតឃើញមានតួអង្គព្រាហ្មណ៍ប្រូចទឹកប្រោះព្រំសិរីសួស្តី មានអ្នកហែហម ភ្លេង និងរបាំកំដរផង។ ទំនៀមដដែលនេះ នៅសាលាឆាន់វត្តអង្គសិម្ពលី ក្នុងខេត្តកណ្តាល គេគូរកូនកំលោះ និងកូនក្រមុំក្រាបសំពះផ្ទឹម ហើយលោកអាចារ្យជាអ្នកឱ្យពរ (រូបលេខ២៧)។



*រូបលេខ២៦ ពិធីរៀបអភិសេកព្រះសិទ្ធត្ថនិងព្រះនាងពិម្ពានៅវត្តកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង*



*រូបលេខ២៧ គំនូរវត្តអង្គសិម្ពលី (រូបថត៖ សាន ផល្ញា)*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែកគំនូរនៅតាមវត្តខ្លះ នៅត្រង់ពិធីរៀបអភិសេក គេគូរបង្ហាញកូនកំលោះ កូនក្រមុំ ពោលគឺព្រះសិទ្ធត្ថនិងព្រះនាងពិម្ពា យាងទន្ទឹមគ្នាចុះតាមជណ្ដើរមានអ្នកបាំងក្ងស់ជាដើម។ មិនតែប៉ុណ្ណោះ បើនៅវត្តអង្គរខាងជើង ក្នុងខេត្តសៀមរាប គេគូរបង្ហាញទិដ្ឋភាពពិធីរៀបអភិសេកព្រះរាមនិងព្រះនាងសីតា ដែលមានលំនាំដូចការរៀបអភិសេកព្រះសិទ្ធត្ថនិងព្រះនាងពិម្ពាដែរ(រូបលេខ៨)។ ប៉ុន្តែនៅវត្តព្រះស៊ីសុវត្ថិរតនារាម ក្នុងស្រុកកោះធំ ខេត្តកណ្ដាល គេបានគូរទិដ្ឋភាពអាពាហ៍ពិពាហ៍មួយដ៏គួរឱ្យចាប់អារម្មណ៍។ ក្នុងគំនូរបង្ហាញរបៀបបែបអ្នកស្រុក មានភ្លេង និងមានអ្នករាំផង(រូបលេខ៩)។


រូបលេខ៨ ពិធីរៀបអភិសេកព្រះរាម និងព្រះនាងសីតា នៅវត្តអង្គរខាងជើង


រូបលេខ៩ ពិធីរៀបមង្គលការរបស់អ្នកស្រុក(?) គូរនៅព្រះវិហារវត្តស៊ីសុវត្ថិរតនារាម

ទោះយ៉ាងណាក្ដី ប្រសិនបើពិនិត្យលម្អិតលើសិល្បៈគំនូរត្រង់ពិធីរៀបអភិសេកដូចរៀបរាប់ត្រួសៗមកពីខាងដើម គេឃើញភាគច្រើនគូរបង្ហាញត្រង់កិច្ចសំពះផ្ទឹម។ ប៉ុន្តែអ្វីដែលគួរសង្កេត គឺជាទូទៅឃើញមានដាវនៅលើដៃកូនកំលោះកូនក្រមុំជានិច្ច តែតួអង្គកូនកំលោះជួនកាលអង្គុយសំពះខាងឆ្វេងដៃកូនក្រមុំ ហើយជួនកាលអង្គុយនៅស្ដាំដៃកូនក្រមុំ។ ទំនៀមត្រង់កិច្ចនេះ បើមើលនៅក្នុងក្បួនទម្រង់ការចាស់ទុំតែងបង្គាប់កូនកំលោះអង្គុយផ្ទឹមស្ដាំដៃ[5] ហើយសព្វថ្ងៃក៏ឃើញប្រតិបត្តិបែបនេះតមកដែរ ដូចមានក្នុងរូបថតឯកសារដែលក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានរៀបចំភ្ជាប់ជូនក្នុងឯកសារស្នើសុំចុះពិធីអាពាហ៍ពិពាហ៍ខ្មែរ នៅក្នុងបញ្ជីអង្គការយូណេស្កូជាភស្ដុងតាង(រូបលេខ១០)។

[5] ញ៉ិក នូវ, ១៩៦៥, ទំ.៩៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ១០ កិច្ចសំពះផ្ទឹមក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែរ (រូប៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ)*

ជាសង្ខេបមក គំនូរនៅតាមវត្តអារាមនានានៅក្នុងសង្គមខ្មែរ មិនត្រឹមតែជាការឆ្លុះពីសាច់រឿងពុទ្ធប្រវត្តិ និងរឿងជាតកប៉ុណ្ណោះទេ តែក៏ជាផ្នែកដ៏សំខាន់មួយក្នុងការបង្ហាញ និងថែរក្សានូវអត្តសញ្ញាណជាតិ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរផងដែរ។ តាមរយៈស្នាដៃ និងទេពកោសល្យរបស់ជាងគំនូរ ទិដ្ឋភាពនៃព្រះរាជពិធីច្រត់ព្រះនង្គ័ល និងកិច្ចសំពះផ្ទឹម ក្នុងពិធីអាពាហ៍ពិពាហ៍ បានបញ្ចូលទៅក្នុងសាច់រឿងពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា ដែលទម្រង់ទំនៀមទម្លាប់ទាំងនេះនៅតែត្រូវបានប្រតិបត្តិ និងរក្សាតម្លៃរហូតមកដល់សព្វថ្ងៃ។ ក្នុងអត្ថបទភាគបន្ត ខ្ញុំនឹងលើកយកទិដ្ឋភាពប្រពៃណី ទំនៀមទម្លាប់ផ្សេងទៀត ដែលសង្កេតឃើញមានគូរបញ្ចូលក្នុងរឿងពុទ្ធប្រវត្តិ បន្ថែមលើទំនៀមទាំងពីរនេះ៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ញ៉ិក នូវ

១៩៦៥, *ក្បួនអាពាហ៍ពិពាហ៍*, បណ្ណាគារ នួន ប៊ុត, ភ្នំពេញ

ឈឹម ក្រសេម និង ចាប ពិន

១៩៥១, *ព្រះរាជពិធីទ្វាទសមាស*, ភាគ២, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

Gunapayuta et al,

1998, *Biography of Sakyamuni Buddha*, Sydney

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda*, Kam editions

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION